# ទីបន្ទាល់

អែលឌើរ ដាល្លិន អេក អូក
នៃក្រុមសាវកនៃពួក 12 នាក់

*ចំណេះដឹងគាំទ្រការគោរពប្រណិបត្តិ ហើយការគោរពប្រណិបត្តិបន្ថែមនូវចំណេះដំណឹង*

ទីបន្ទាល់នៃដំណឹងល្អគឺជាសាក្សីផ្ទាល់ខ្លួនដែលកើតមាននៅក្នុងព្រលឹងរបស់យើង ដោយព្រះវិញ្ញាណបរិសុទ្ធថា កត្តាជាក់លាក់មួយចំនួននៃសារៈសំខាន់ដ៏នៅអស់កល្បជានិច្ចគឺពិត ហើយថាយើងដឹងថាកិច្ចការទាំងនេះពិត។ កត្តាបែបនោះ រួមទាំងនិស្ស័យនៃក្រុមព្រះ និងចំណងមិត្តភាពរបស់យើងចំពោះសមាជិកទាំងបីនៃក្រុម ប្រសិទ្ធភាពនៃដង្វាយធួន ហើយភាពពិតនៃការស្តារឡើងវិញ។

ទីបន្ទាល់នៃដំណឹងល្អគឺមិនមែនជារបាយការណ៍ធ្វើដំណើរ របាយការណ៍សុខភាព ឬចំណាប់អារម្មណ៍នៃសេចក្តីស្រឡាញ់ ចំពោះសមាជិកក្រុមគ្រួសារទេ។ វាមិនមែនជាទេសនកថាទេ។ ប្រធាន ឃីមប៊ល បានបង្រៀនថា នៅវិនាទីដែលយើងចាប់ផ្តើមប្រៀនប្រដៅទៅអ្នកដទៃ នោះទីបន្ទាល់របស់យើងត្រូវបញ្ចប់។1

I. មានសំណួរជាច្រើនបានលើកឡើងនៅពេលដែលយើងឮអ្នកដទៃថ្លែងទីបន្ទាល់ ឬនៅពេលយើងពិចារណាធ្វើការថ្លែងទីបន្ទាល់ខ្លួនរបស់យើងផ្ទាល់។

1. នៅក្នុងការប្រជុំទីបន្ទាល់មានសមាជិកម្នាក់និយាយថាៈ "ខ្ញុំដឹងថាព្រះវរបិតា និងព្រះរាជបុត្រាបានបង្ហាញព្រះអង្គទ្រង់ដល់ព្យាការី យ៉ូសែប ស្ម៊ីធ"។ អ្នកមកលេងបានឆ្ងល់ថាៈ "តើគាត់ចង់មានន័យយ៉ាងដូចម្តេចនៅពេលដែលគាត់និយាយថាគាត់ *ដឹងថា* ?"
2. មានយុវជនម្នាក់កំពុងរៀបចំខ្លួនទៅបំរើបេសកកម្ម ឆ្ងល់ថាតើទីបន្ទាល់របស់គាត់រឹងមាំគ្រប់គ្រាន់ ដើម្បីឱ្យគាត់អាចបំរើជាអ្នកផ្សព្វផ្សាយសាសនាបានដែរឬទេ។
3. មនុស្សវ័យក្មេងឮទីបន្ទាល់របស់ឪពុកម្តាយ ឬគ្រូបង្រៀន។ តើទីបន្ទាល់បែបនោះជួយមនុស្សម្នាក់ដែលបានឮទីបន្ទាល់នោះយ៉ាងដូចម្តេចទៅ?

II. តើយើងចង់មានន័យយ៉ាងដូចម្តេចនៅពេលយើងថ្លែងទីបន្ទាល់ ហើយនិយាយថាយើង *ដឹង* ថាដំណឹងល្អគឺពិត? ផ្ទុយពីចំណេះដឹងបែបនោះជាមួយនឹង "ខ្ញុំដឹងថាវាត្រជាក់នៅខាងក្រៅ" ឬ "ខ្ញុំដឹងថាខ្ញុំស្រឡាញ់ភរិយារបស់ខ្ញុំ"។ ទាំងនេះគឺជាចំណេះដឹងខុសគ្នាបីយ៉ាង ចំណេះដឹងនីមួយៗរៀនតាមវិធីខុសៗគ្នា។ ចំណេះដឹងនៃសីតុណ្ហភាពខាងក្រៅអាចត្រូវគូសបញ្ជាក់ដោយការបំភ្លឺខាងវិទ្យាសាស្ត្រ។ ចំណេះដឹងដែលថាយើងស្រឡាញ់ប្តីប្រពន្ធរបស់យើង គឺមានលក្ខណៈផ្ទាល់ខ្លួន និងបុគ្គល។ ទោះបីជាគ្មានការស្រាយបំភ្លឺពីខាងវិទ្យាសាស្ត្រក្តី វានៅតែសំខាន់។ គំនិតដែលថាចំណេះដឹងដែលសំខាន់ៗទាំងអស់គឺពឹងផ្អែកទៅលើភស្តុតាងខាងវិទ្យាសាស្ត្រគឺជាធម្មតាមិនមែនជាការពិតទេ។
ទោះបីជាមាន "ភស្តុតាង" សំរាប់សេចក្តីពិតនៃដំណឹងល្អក្តី (ជាឧទាហរណ៍ សូមមើលទំនុកដំកើង 19:1 ហេលេមិន 8:24) យុទ្ធសាស្ត្រខាងវិទ្យាសាស្ត្រនឹងមិននាំឱ្យមានចំណេះដឹងខាងវិញ្ញាណឡើយ។ នេះគឺជាអ្វីដែលព្រះយេស៊ូវ

បានបង្រៀន នៅក្នុងការឆ្លើយតបចំពោះទីបន្ទាល់របស់ស៊ីម៉ូន-ពេត្រុសថា ទ្រង់គឺជាព្រះគ្រីស្ទ: "ស៊ីម៉ូន កូនយ៉ូណាស អើយ អ្នកមានពរ ត្បិតមិនមែនជាសាច់ ឈាមដែលបានសម្តែងឱ្យអ្នកស្គាល់ទេ គឺព្រះវរបិតានៃខ្ញុំដែលគង់នៅស្ថានសួគ៌វិញ" (ម៉ាថាយ 16:17)។ សាវកប៉ុល បានពន្យល់ពីការណ៍នេះ។ នៅក្នុងសំបុត្រទៅកាន់ពួកបរិសុទ្ធកូរិនថូស គាត់បាននិយាយថា: "មិនមែនជាវិញ្ញាណនៃព្រះនោះក៏គ្មានអ្នកណាស្គាល់ស្គាល់សណ្ឋានព្រះបានដែរ" (កូរិនថូទី1 2:11 សូមមើលផងដែរ យ៉ូហាន 14:17)។

ផ្ទុយទៅវិញ យើងដឹងនូវកិច្ចការទាំងឡាយនៃមនុស្ស តាមវិធីសាស្ត្ររបស់មនុស្ស ប៉ុន្តែ "មនុស្សខាងសាច់ឈាម គេមិនទទួលសេចក្តីខាងឯព្រះវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្តីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ត្បិតឯសេចក្តីទាំងនោះត្រូវពិចារណាយល់ខាងវិញ្ញាណវិញ" (កូរិនថូសទី1 2:14)។

ព្រះគម្ពីរមរមនបង្រៀនថា ព្រះនឹងបង្ហាញនូវសេចក្តីពិតនូវរឿងខាងវិញ្ញាណចំពោះយើង ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ (សូមមើល មរ៉ូណៃ 10:4--5)។ នៅក្នុងវិវរណៈសម័យទំនើបព្រះបានសន្យានឹងយើងថា បើយើងទទួល "ចំណេះដឹង" ដោយទ្រង់បានប្រាប់យើងនៅក្នុងគំនិត និងនៅក្នុងដួងចិត្តរបស់យើង "ដោយព្រះវិញ្ញាណបរិសុទ្ធ" (គ. និង ស. 8:1--2)។

កិច្ចការដ៏មហិមាមួយនៃកិច្ចការទាំងឡាយអំពីផែនការរបស់ព្រះវរបិតាសួគ៌របស់យើង សំរាប់កូនចៅរបស់ទ្រង់ គឺថាយើងម្នាក់ៗអាចដឹងនូវសេចក្តីពិតនៃផែនការនោះសំរាប់ខ្លួនរបស់យើងផ្ទាល់។ ចំណេះដឹងដែលបានបើកសម្តែងនោះ មិនបានមកតាមរយៈសៀវភៅ ការស្រាយបំភ្លឺខាងវិទ្យាសាស្ត្រទេ ឬចេញពីការសញ្ជឹងគិតខាងបញ្ញានោះដែរ។ ដូចជាសាវក ពេត្រុស យើងអាចទទួលចំណេះដឹងនោះដោយផ្ទាល់មកពីព្រះវរបិតាសួគ៌របស់យើង តាមរយៈទីបន្ទាល់នៃព្រះវិញ្ញាណបរិសុទ្ធ។

នៅពេលដែលយើងដឹងពីសេចក្តីពិតខាងវិញ្ញាណ តាមរយៈមធ្យោបាយខាងវិញ្ញាណ នោះយើងក៏អាចទទួលចំណេះដឹងយ៉ាងពិតប្រាកដដូចជាអ្នកប្រាជ្ញ ឬអ្នកវិទ្យាស្រ្តផងដែលមានចំណេះដឹងខុសៗគ្នា ដោយពួកគេបានរៀនតាមវិធីសាស្ត្រខុសៗគ្នាផងដែរ។

ព្យាការីយ៉ូសែប ស្ម៊ីធ បានផ្តល់ឱ្យនូវឧទាហរណ៍ដ៏អស្ចារ្យអំពីកិច្ចការនេះ។ នៅពេលដែលលោកត្រូវបានបៀតបៀនដោយសារការប្រាប់ប្រជាជនអំពីការនិមិត្តរបស់លោក លោកបានប្រៀបប្រដូចកាលៈទេសៈរបស់លោកដូចជាសាវកប៉ុលដែលត្រូវបានចំអក ហើយជេរប្រមាថនៅពេលគាត់ធ្វើការការពារ ពីមុខព្រះករុណាអ័គ្រីប៉ា (សូមមើល កិច្ចការ 26)។ លោកយ៉ូសែប បានមានប្រសាសន៍ថា "ប៉ុន្តែការណ៍ទាំងអស់នេះពុំបានបំផ្លាញនូវការពិត អំពីការនិមិត្តដែលលោកបានឃើញនោះឡើយ"។ លោកយ៉ូសែប បានបន្តថា "លោកបានឃើញការនិមិត្ត លោកដឹងថា លោកបានឃើញមែន ហើយអស់ទាំងការបៀតបៀននៅក្រោមមេឃទាំងឡាយ ក៏មិនអាចប្រែការណ៍នោះបានដែរ...។ ម្ល៉ោះហើយរឿងនោះក៏ដូចជារឿងខ្ញុំដែរ"។ "ខ្ញុំពិតជាបានឃើញពន្លឺមែន ហើយនៅកណ្តាលពន្លឺនោះ ខ្ញុំបានឃើញតួអង្គពីរ ហើយតួអង្គនោះបានមានព្រះបន្ទូលមកខ្ញុំជាពិតប្រាកដ...។ ខ្ញុំដឹងថាខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំដឹងថា ព្រះទ្រង់ក៏ដឹងថាខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំពុំអាចបដិសេធរឿងនេះ ឬហ៊ានធ្វើយ៉ាងដូច្នោះបានឡើយ"(យ៉ូសែប ស្ម៊ីធ--ប្រវត្តិ 1:24--25)។

III. នោះគឺជាទីបន្ទាល់របស់លោកយ៉ូសែប ស៊្មីធ។ ចុះចំណែកទីបន្ទាល់របស់យើងវិញ? តើយើងអាចដឹង ហើយថ្លែងទីបន្ទាល់ថាអ្វីដែលលោកបាននិយាយគឺជាការពិតដែរឬទេ? តើមនុស្សម្នាក់អាចទទួលបានអ្វីដែលយើងហៅថាទីបន្ទាល់យ៉ាងដូចម្ដេច?

ជំហ៊ានទីមួយនៅក្នុងការកើននូវរាល់ចំណេះដឹងគ្រប់ប្រភេទគឺបំណងប្រាថ្នាពិតប្រាកដដែលចង់ដឹង។ នៅក្នុងករណីចំណេះដឹងខាងវិញ្ញាណ ជំហ៊ានបន្ទាប់គឺត្រូវសួរព្រះនៅក្នុងការអធិស្ឋានដោយចិត្តស្មោះស។ ដូចដែលយើងបានអាននៅក្នុងវិវរណៈសម័យទំនើបថា "បើសិនជាអ្នកសូម នោះអ្នកនឹងបានទទួលវិវរណៈថែមទៅលើវិវរណៈ គំនិតថែមទៅលើគំនិត ដើម្បីឱ្យអ្នកអាចបានស្គាល់សេចក្ដីអាថ៌កំបាំងទាំងឡាយ និងរបស់ទាំងឡាយដ៏ប្រកបដោយសេចក្ដីសុខសាន្ត---ដែលនឹងនាំឱ្យមានសេចក្ដីអំណរ ជាអ្វីដែលនាំឱ្យមានជីវិតដ៏នៅអស់កល្បជានិច្ច" (គ. និង ស. 42:61)។

នេះគឺជាអ្វីដែលអាលម៉ា បានសរសេរអំពីអ្វីដែលគាត់បាននិយាយថា: "មើលចុះខ្ញុំសូមប្រាប់អ្នកថា រឿងទាំងនោះគឺព្រះវិញ្ញាណបរិសុទ្ធនៃព្រះទ្រង់បានប្រាប់ដល់ខ្ញុំ។ មើលចុះ ខ្ញុំបានតមអាហារ ហើយបានអធិស្ឋានជាច្រើនថ្ងៃ ដើម្បីខ្ញុំអាចដឹងនូវរឿងទាំងនេះដោយខ្លួនខ្ញុំ។ ហើយឥឡូវនេះ ខ្ញុំដឹងរឿងទាំងនោះដោយខ្លួនខ្ញុំថាជារឿងពិត ព្រោះព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានសម្ដែងប្រាប់ខ្ញុំ ដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់" (អាលម៉ា 5:46)។

នៅពេលដែលយើងមានបំណងប្រាថ្នាដើម្បីស្វែងយល់ នោះយើងគួរតែចងចាំថាការទទួលបានទីបន្ទាល់គឺមិនមែនជារឿង ដែលហុចតគ្នាបានទេ ប៉ុន្តែជាដំណើរការដែលយើងត្រូវបានរំពឹងទុកឱ្យ *ធ្វើ* អ្វីមួយ។ ព្រះយេស៊ូវបានបង្រៀនថា "បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងជាសេចក្ដីបង្រៀននេះមកពីព្រះ ឬជាខ្ញុំនិយាយដោយអាងខ្លួនខ្ញុំ" (យ៉ូហាន 7:17)។

វិធីផ្សេងទៀតដើម្បីស្វែងរកទីបន្ទាល់ហាក់ដូចជាអស្ចារ្យណាស់ បើប្រៀបធៀបជាមួយនឹងវិធីសាស្ត្រនៃការទទួលបានចំណេះវិជ្ជាផ្សេងទៀត។ យើងកើន ឬពង្រឹងទីបន្ទាល់របស់យើងដោយការថ្លែងវា។ មនុស្សខ្លះថែមទាំងបានស្នើថា ទីបន្ទាល់របស់មនុស្សខ្លះទទួលបានដោយការថ្លែងទីបន្ទាល់ ជាជាងដោយការលុតជង្គង់ចុះដើម្បីអធិស្ឋានសុំទីបន្ទាល់។

ទីបន្ទាល់ផ្ទាល់ខ្លួនគឺជាគ្រឹះចំពោះសេចក្ដីជំនឿរបស់យើង។ ជាញឹកញាប់ កិច្ចការដែលយើងធ្វើដើម្បីទទួលបានការពង្រឹង និងរក្សាទីបន្ទាល់គឺសំខាន់ចំពោះជីវិតខាងវិញ្ញាណរបស់យើង។ ជាការបន្ថែម ចំពោះវិធីទទួលបានទីបន្ទាល់ដែលបាននិយាយរួចមកហើយ យើងត្រូវតែទទួលទាននូវសាក្រាម៉ង់ជារៀងរាល់សប្ដាហ៍ (សូមមើល គ. និង ស. 59:9) ដើម្បីមានភាព សក្ដិសមសំរាប់ការសន្យាដ៏វិសេសវិសាលដែលយើងនឹង "បានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយនឹង [យើង] ជានិច្ច" (គ. និង ស. 20:77)។ ពិតប្រាកដណាស់ ព្រះវិញ្ញាណនោះគឺជាប្រភពនៃទីបន្ទាល់របស់យើង។

IV. ជនទាំងឡាយនាដែលមានទីបន្ទាល់ពីដំណឹងល្អដែលបានស្ដារឡើងវិញ ក៏មានតួនាទីដើម្បីចែកចាយពីដំណឹងល្អផងដែរ។ ព្រះគម្ពីរមរមន បង្រៀនថាយើងគួរតែ "ឈរជាសាក្សីដល់ព្រះនៅគ្រប់ពេល និងគ្រប់សេចក្ដី និងគ្រប់ទីកន្លែងដែល [យើង] ណានៅ..." (ម៉ូសាយ 18:9)។

ការបង្រៀនមួយដ៏គួរឱ្យចាប់អារម្មណ៍នៅក្នុងចំណោមការបង្រៀនទាំងឡាយ ស្តីអំពីចំណងមិត្តភាពរវាងអំណោយទាននៃទីបន្ទាល់ និងតួនាទីដើម្បីថ្លែងទីបន្ទាល់គឺនៅក្នុងកណ្ឌទី 46 នៃព្រះគម្ពីរគោលលទ្ធិ និង សេចក្តីសញ្ញា។ ក្នុងការពិពណ៌នាពីអំណោយទានខុសៗគ្នាខាងវិញ្ញាណដែលវិវរណៈនេះបានថ្លែងៈ

"ចំពោះមនុស្សខ្លះ ត្រូវបានប្រទានដោយព្រះវិញ្ញាណបរិសុទ្ធ ឱ្យដឹងថា ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះ ហើយថាទ្រង់ត្រូវគេឆ្កាងជំនួសអំពើបាបទាំងឡាយនៃមនុស្សលោក។

"ចំពោះមនុស្សខ្លះទៀត ត្រូវបានប្រទានឱ្យជឿដល់ពាក្យពេចន៍នៃពួកគេ ប្រយោជន៍ឱ្យពួកគេអាចមានជីវិតដ៏នៅអស់កល្បជានិច្ចផងដែរ បើសិនជាពួកគេមានចិត្តស្មោះត្រង់រហូតតទៅ" (ខទី 13--14 សូមមើលផងដែរ យ៉ូហាន 20:29)។

ជនទាំងឡាយណាដែលមានអំណោយទានដើម្បី *ដឹង* មានតួនាទីយ៉ាងសំខាន់ដើម្បីថ្លែងទីបន្ទាល់របស់ពួកគេ ដើម្បីជនទាំងឡាយណាដែលមានអំណោយទានដើម្បី *ជឿទៅលើពាក្យពេចន៍របស់ពួកគេ* អាចមានជីវិតដ៏នៅអស់កល្បជានិច្ចផងដែរ។

មិនដែលធ្លាប់មានសេចក្តីត្រូវការដែលមហិមាជាងនេះ សំរាប់យើងដើម្បីអះអាងពីសេចក្តីជំនឿរបស់យើង ជាលក្ខណៈឯកជន និងជាលក្ខណៈសាធារណៈ (សូមមើល គ. និង ស. 60:2)។ ទោះបីជា មានការប្រកាសថាគ្មានព្រះក្តី ក៏មានមនុស្សជាច្រើនដែលបានបើកចិត្តចំពោះសេចក្តីពិតបន្ថែមទៀតអំពីព្រះផងដែរ។ ចំពោះជនដែលស្វែងរកដោយស្មោះសទាំងនេះ យើងត្រូវអះអាងនូវការរស់នៅនៃព្រះជាព្រះវរបិតាដ៏អស់កល្បជានិច្ច បេសកកម្មដ៏ទេវភាពនៃព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់យើង ព្រះយេស៊ូវគ្រីស្ទ និងការពិតនៃការស្តារឡើងវិញ។ យើងត្រូវតែក្លាហានក្នុងទីបន្ទាល់របស់យើងពីព្រះយេស៊ូវ។ យើងម្នាក់ៗមានឱកាសជាច្រើន ចំពោះការប្រកាសជំនឿខាងវិញ្ញាណរបស់យើង ចំពោះមិត្តភក្តិ និងអ្នកជិតខាង ទៅអ្នករួមការងារ និងទៅមនុស្សដែលស្គាល់ធម្មតា។ យើងគួរតែប្រើប្រាស់ឱកាសទាំងនេះ ដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់យើងសំរាប់ព្រះអង្គសង្គ្រោះរបស់យើង សាក្សីរបស់យើងពីបេសកកម្មដ៏ទេវភាពរបស់ទ្រង់ និងការប្តេជ្ញាចិត្តរបស់យើងដើម្បីបំរើទ្រង់។ 2 កូនចៅរបស់យើងគួរតែបានឮពីទីបន្ទាល់របស់យើងជាញឹកញាប់ផងដែរ។ យើងគួរតែពង្រឹងកូនចៅរបស់យើង ដោយការលើកទឹកចិត្តពួកគេឱ្យស្គាល់ខ្លួនរបស់ពួកគេតាមរយៈ ទីបន្ទាល់របស់ពួកគេដែលបានរីកចំរើនផងដែរ មិនគ្រាន់តែតាមរយៈការទទួលស្គាល់របស់ពួកគេនៅក្នុងអាហាររូបករណ៍ កីឡា ឬសកម្មភាពកីឡាផ្សេងទៀតនោះទេ។

V. យើងរស់នៅក្នុងសម័យដែលនៅពេលនរណាម្នាក់បង្ហាញខុសនូវជំនឿនៃជនទាំងឡាយណាដែលពួកគេហៅថាពួកមរមន ហើយថែមទាំងប្រមាថដល់យើង ពីព្រោះតែគោលលទ្ធិទាំងនេះ។ នៅពេលយើងជួបប្រទះនូវការបង្ហាញខុសបែបនោះ នោះយើងមានតួនាទីដើម្បីនិយាយប្រាប់ដើម្បីបញ្ជាក់ពីគោលលទ្ធិរបស់យើង និងអ្វីដែលយើងជឿ។ យើងគួរតែជា បុគ្គលដែលបង្ហាញជំនឿរបស់យើង ជាជាងការអនុញ្ញាតឱ្យអ្នកដទៃអាកាត់នូវការបង្ហាញខុសឆ្គងអំពីគោលលទ្ធិទាំងឡាយ។ ការណ៍នេះតំរូវឱ្យមានទីបន្ទាល់ ដែលអាចបង្ហាញជាឯកជនចំពោះអ្នកដែលយើងស្គាល់ ឬជាសាធារណៈនៅក្នុងការប្រជុំតូច ឬធំ ។ នៅពេលយើងថ្លែងទីបន្ទាល់ពីសេចក្តីពិតដែល យើងដឹង យើងគួរតែធ្វើតាមដោយស្មោះត្រង់នូវការដាស់តឿនឱ្យនិយាយ "ដោយទន់ភ្លន់ និងស្លូតបូត" (គ. និង ស. 38:41)។

យើងមិនគួរអួតអាង និយាយពាក្យគំរោះគំរើយ ឬការប្រមាថនោះទេ។ ដូចដែលសាវកប៉ុលបានបង្រៀនថាៈ យើងគួរតែនិយាយសេចក្តីពិតដោយសេចក្តីស្រឡាញ់ (សូមមើល អេភេសូរ 4:15)។ មនុស្សគ្រប់រូបអាចមិនឯកភាព ជាមួយនឹងទីបន្ទាល់ផ្ទាល់ខ្លួនរបស់យើង ប៉ុន្តែគ្មាននរណាម្នាក់អាចបដិសេធន៍ទីបន្ទាល់នោះបានឡើយ។

VI. ជាទីបញ្ចប់ ខ្ញុំសូមនិយាយពីចំណងមិត្តភាពរវាងការប្រណិបត្តិ និងចំណេះដឹង។ សមាជិកទាំងឡាយដែលមាន ទីបន្ទាល់ ហើយនរណាដែលប្រព្រឹត្តចំពោះទីបន្ទាល់នៅក្រោមការដឹកនាំ នៃពួកអ្នកដឹកនាំសាសនាចក្ររបស់ពួកគេ គឺពេលខ្លះបានត្រូវចោទប្រកាន់ពីការគោរពប្រណិបត្តិដែលងងឹតងងល់។

ពិតប្រាកដណាស់ យើងមានពួកអ្នកដឹកនាំ ហើយពិតណាស់យើងគឺស្ថិតក្រោមការសំរេចចិត្តរបស់ពួកគេ និងការណែនាំ នៅក្នុងដំណើរនៃសាសនាចក្រ និងនៅក្នុងការអនុវត្តន៍នៃពិធីការបព្វជិតភាពដែលចាំបាច់ទាំងឡាយ។ ប៉ុន្តែនៅពេលដែលការរៀនសូត្រ និងការយល់ដឹងនូវសេចក្តីពិតនៃដំណឹងល្អ---ទីបន្ទាល់ផ្ទាល់របស់យើងបានមកដល់---យើងម្នាក់ៗមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងព្រះ ដែលជាព្រះវរបិតាដ៏អស់កល្បជានិច្ចរបស់យើង និងព្រះរាជបុត្រា របស់ទ្រង់គឺព្រះយេស៊ូវគ្រីស្ទតាមរយៈទីបន្ទាល់ដ៏មានព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ។ នេះគឺជាអ្វីដែល ពួកអ្នកទិទៀន របស់យើងបរាជ័យចំពោះការយល់ដឹង។ វាធ្វើការណ៍នេះចូលគ្នាដែលយើងអាចសាមគ្គីគ្នានៅក្នុងការធ្វើ តាមពួកអ្នកដឹកនាំ របស់យើង ហើយជាងនេះទៅទៀតនៅក្នុងការដឹងសំរាប់ខ្លួនដោយឯករាជ្យភាព។

ប្រហែលជាការផ្ទុំទាំងនោះធ្វើឱ្យអ្នកខ្លះមានអារម្មណ៍ថាអាចត្រូវបានពន្យល់ដោយធាតុពិត ដែលយើងម្នាក់ៗមាន វិធីពីរផ្សេងៗគ្នាដើម្បីទាក់ទងនឹងព្រះ។ យើងមានវិធីនៃការគ្រប់គ្រងតាមរយៈព្យាការីរបស់យើង និងពួកអ្នកដឹកនាំ ដទៃទៀត។ ទំនាក់ទំនងនេះដែលទាក់ទងជាមួយនឹងគោលលទ្ធិ ពិធីការ និងព្រះបញ្ញត្តិទាំងឡាយ ជាលទ្ធផលនៃ ការប្រណិបត្តិ។ យើងក៏មានទំនាក់ទំនងនៃទីបន្ទាល់ផ្ទាល់ខ្លួនដែលភ្ជាប់ចំពោះព្រះដោយផ្ទាល់។ ការណ៍នេះត្រូវតែធ្វើ ជាមួយនឹងការរស់នៅរបស់ទ្រង់ ចំណងមិត្តភាពរបស់យើងចំពោះទ្រង់ និងសេចក្តីពិតនៃដំណឹងល្អរបស់ទ្រង់ដែលបាន ស្តារឡើងវិញ។ ទំនាក់ទំនងនេះជាលទ្ធផលដោយសារចំណេះវិជ្ជា។ ទំនាក់ទំនងទាំងពីរនេះគឺគាំទ្រគ្នាទៅវិញទៅមកៈ ចំណេះដឹងលើកទឹកចិត្តដល់ការគោរពប្រណិបត្តិ (សូមមើល ចោទិយកថា 5:27 ម៉ូសេ 5:11)ហើយការប្រណិបត្តិធ្វើឱ្យ កើនឡើងនូវចំណេះដឹង (សូមមើលយ៉ូហាន 7:17 គ. និង ស. 93:1)។

យើងទាំងអស់គ្នាធ្វើទង្វើទៅតាម ឬផ្តល់ការប្រណិបត្តិចំពោះចំណេះដឹង។ មិនថាជាវិទ្យាសាស្រ្ត ឬសាសនានោះ ទេ ការប្រណិបត្តិរបស់ពួកយើងគឺមិនងងឹតងងល់ទេ នៅពេលយើងធ្វើទង្វើទៅតាមចំណេះដឹងសក្តិសមនឹងប្រធានបទ នៃសកម្មភាពរបស់យើង។ អ្នកវិទ្យាសាស្រ្តម្នាក់ទទួល ហើយធ្វើទង្វើស្របតាមសញ្ញាប័ត្រដែលត្រូវបានគេទុកចិត្ត នៃមាតិកា ឬស្ថានភាពនៃការពិសោធន៍ជាក់លាក់មួយ។ តាមបញ្ហាសាសនា ប្រភពនៃចំណេះដឹងរបស់អ្នកជឿគឺ ខាងវិញ្ញាណ ប៉ុន្តែគោលការណ៍គឺដូចគ្នា។ នៅក្នុងករណីនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធ បានប្រទានដល់ព្រលឹងរបស់យើងនូវទីបន្ទាល់នៃសេចក្តីពិត នៃដំណឹងល្អដែលបានស្តារឡើងវិញ ហើយការហៅនៃ ព្យាការីសម័យទំនើប ជំរើសរបស់យើងដើម្បីធ្វើតាមការបង្រៀនទាំងឡាយ គឺមិនមែនជាការប្រណិបត្តិដោយងងឹត ងងល់នោះទេ។

នៅក្នុងទីបន្ទាល់របស់យើងទាំងអស់ យើងត្រូវតែជៀសវាងនូវឫកពារកោងកាច និងអំនួត។ យើងគួរតែចងចាំថា ព្រះគម្ពីរមរមនបន្ទោសដល់ប្រជាជនដែលមានអំនួតបែបនោះ ដោយសាររបស់របរដ៏មហិមាជាច្រើនដែលព្រះបានប្រទានដល់ពួកគេ ដែលអំនួតពួកគេធ្វើឱ្យក្ដៅក្រហាយដល់ពួកអ្នកជិតខាងរបស់ពួកគេ (សូមមើល យ៉ាកុប 2:20)។ យ៉ាកុបបាននិយាយថាការណ៍ទាំងនេះថាជា "ការគួរឱ្យខ្ពើមឆ្អើមចំពោះព្រះដែលបានបង្កើតសាច់ឈាមទាំងអស់មក" ពីព្រោះ "នៅក្រោមព្រះនេត្រទ្រង់មនុស្សណាក៏មានតម្លៃ ដូចជាមនុស្សណាដែរ" (យ៉ាកុប 2:21)។ ក្រោយមកអាលម៉ាបានដាស់តឿនថា "អ្នករាល់គ្នាមិនត្រូវលើកដំកើងមនុស្សម្នាក់ ជាងមនុស្សម្នាក់ទៀតឡើយ ឬបុរសម្នាក់មិនត្រូវគិតថា ខ្លួនខ្ពស់ជាងម្នាក់ទៀតទេ" (ម៉ូសាយ 23:7)។

ខ្ញុំសូមបិទជាមួយនឹងទីបន្ទាល់របស់ខ្ញុំ។ ខ្ញុំដឹងថា យើងមានព្រះវរបិតាសួគ៌ដែលផែនការរបស់ទ្រង់នាំយើងមកកាន់ផែនដី ហើយផ្ដល់ឱ្យយើងនូវស្ថានភាពជាច្រើន ហើយជោគវាសនានៃការធ្វើដំណើរដ៏អស់កល្បជានិច្ចរបស់យើង។ ខ្ញុំដឹងថា យើងមានព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ដែលការបង្រៀនទាំងឡាយបង្ហាញនូវផែនការ ហើយដែលដង្វាយធួនរបស់ទ្រង់ផ្ដល់ឱ្យនូវការធានានៃអមតភាព និងឱកាសសំរាប់ជីវិតដ៏នៅអស់កល្បជានិច្ច។ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌ និងព្រះរាជបុត្រាបានបង្ហាញព្រះអង្គទ្រង់ចំពោះព្យាការីយ៉ូសែប ស៊្មីធ ដើម្បីស្ដារនូវភាពពេញលេញនៃដំណឹងល្អនៅសម័យចុងក្រោយទាំងនេះ។ ហើយខ្ញុំដឹងថា យើងត្រូវបានដឹកនាំសព្វថ្ងៃនេះដោយព្យាការី គឺប្រធាន ថូម៉ាស អេស ម៉ុនសុន ដែលកាន់កូនសោទាំងអស់ដើម្បីអនុញ្ញាតឱ្យដល់អ្នកកាន់បព្វជិតភាព សម្ដែងនូវពិធីការទាំងឡាយដែលជាតំរូវការសំរាប់ ការរីកចំរើនរបស់យើងឆ្ពោះទៅរកជីវិតដ៏នៅអស់កល្បជានិច្ច។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. *សូមមើល* *Teachings of Spencer W. Kimball* កែសំរួលដោយ អេឌ្វីដ អិល. គីមបុល ឆ្នាំ 1982 ទំព័រ 138។

3. ជាឧទាហរណ៍ សូមមើល Jeanne Newman, "With the Sound of a Trump," *Tambuli* ខែ សីហា ---ខែ កញ្ញា ឆ្នាំ 1985, 21--23។